ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ៣៧៥.........សហវ.បក

# ប្រកាសអន្តរក្រសួង
## ស្តីពី
## ចំនួននិងនីតិវិធីនៃការអនុវត្តចំណាយ
## កញ្ចប់ថវិកាសម្រាប់ប្រតិបត្តិការពង្រឹងគុណភាពនិងលើកកម្ពស់សមធម៌សេវាសុខាភិបាល
## ចំពោះមន្ទីរពេទ្យបង្អែក និងមណ្ឌលសុខភាព នៃក្រសួងសុខាភិបាល

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ** **រដ្ឋមន្ត្រីក្រសួងសុខាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី ២១ ខែធ្នូ ឆ្នាំ ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី ១៦ ខែតុលា ឆ្នាំ ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៦៧ អនក្រ.បក ចុះថ្ងៃទី ២២ ខែតុលា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសុខាភិបាល

- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី ១៦ ខែវិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីបទបញ្ញត្តទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៧៤ អនក្រ.បក ចុះថ្ងៃទី ២២ ខែឧសភា ឆ្នាំ ២០១២ ស្តីពីការដាក់ឱ្យប្រើប្រាស់នីតិវិធីរួមបច្ចុប្បន្នកម្ម សម្រាប់ការអនុវត្តគម្រោងហិរញ្ញប្បទានសហប្រតិបត្តិការពីដៃគូអភិវឌ្ឍន៍
- យោងតម្រូវការចាំបាច់ក្នុងការពង្រឹងគុណភាពសេវាសុខាភិបាល នៅតាមមន្ទីរពេទ្យបង្អែក និងមណ្ឌលសុខភាពនៃក្រសួងសុខាភិបាល

**សម្រេច**

**ជំពូកទី១**

**បទប្បញ្ញត្តិទូទៅ**

**ប្រការ ១.-**

ប្រកាសនេះ មានគោលដៅកំណត់វិធាននិងនីតិវិធីនៃការអនុវត្តចំណាយកញ្ចប់ថវិកាសម្រាប់ប្រតិបត្តិការពង្រឹងគុណភាព និងលើកកម្ពស់សមធម៌សេវាសុខាភិបាល ចំពោះមន្ទីរពេទ្យបង្អែក និងមណ្ឌលសុខភាពនៃក្រសួងសុខាភិបាល។

**ប្រការ ២.-**

ប្រកាសនេះ មានគោលបំណងដូចតទៅ ÷

- សម្រួលនីតិវិធីនៃការអនុវត្តចំណាយ កញ្ចប់ថវិកាសម្រាប់ប្រតិបត្តិការ ពង្រឹងគុណភាព និងលើកកម្ពស់សមធម៌សេវាសុខាភិបាល ដើម្បីលើកកម្ពស់ការផ្តល់សេវាសុខាភិបាលប្រកបដោយប្រសិទ្ធិភាព គុណភាព និងសមធម៌
- ពង្រឹងនិងបង្កើនគណនេយ្យភាព និងតម្លាភាព នៃការគ្រប់គ្រងនិងការអនុវត្តចំណាយ កញ្ចប់ថវិកាសម្រាប់ប្រតិបត្តិការពង្រឹងគុណភាព និងលើកកម្ពស់សមធម៌សេវាសុខាភិបាល ចំពោះមន្ទីរពេទ្យបង្អែក និងមណ្ឌលសុខភាព។

**ប្រការ ៣.-**

ប្រកាសនេះ មានវិសាលភាពអនុវត្តចំពោះមន្ទីរពេទ្យបង្អែក និងមណ្ឌលសុខភាពដែលស្ថិតក្នុងក្របខ័ណ្ឌសមត្ថកិច្ចនៃក្រសួងសុខាភិបាល លើកញ្ចប់ថវិកាសម្រាប់ប្រតិបត្តិការពង្រឹងគុណភាព និងលើកកម្ពស់សមធម៌សេវាសុខាភិបាល ។

**ប្រការ ៤.-**

សម្រាប់ការអនុវត្តប្រកាសនេះ ពាក្យ "មន្ទីរពេទ្យបង្អែក" និង "មណ្ឌលសុខភាព" ត្រូវបានសំដៅទៅលើមន្ទីរពេទ្យបង្អែក និងមណ្ឌលសុខភាព នៅក្នុងក្របខ័ណ្ឌសមត្ថកិច្ចនៃក្រសួងសុខាភិបាល ។

កញ្ចប់ថវិកាសម្រាប់ប្រតិបត្តិការពង្រឹងគុណភាព និងលើកកម្ពស់សមធម៌សេវាសុខាភិបាល សំដៅដល់ថវិកាជាតិ ដែលត្រូវផ្តល់ជូនដល់មន្ទីរពេទ្យបង្អែក និងមណ្ឌលសុខភាព នៅក្នុងក្របខ័ណ្ឌសមត្ថកិច្ចនៃក្រសួងសុខាភិបាល ដើម្បីចាត់ចែងអនុវត្តចំណាយផ្ទាល់ ក្នុងគោលដៅលើកកម្ពស់គុណភាព សមភាពនិងសមធម៌។

មន្ត្រីគ្រប់គ្រងហិរញ្ញវត្ថុគឺជាមន្ត្រី មន្ទីរពេទ្យបង្អែក ឬ មណ្ឌលសុខភាព ដែលមានសមត្ថភាពក្នុងការអនុវត្តកិច្ច ប្រតិបត្តិការហិរញ្ញវត្ថុដោយត្រូវគោរពតាមវិធាន និងបទប្បញ្ញត្តិហិរញ្ញវត្ថុជាធរមាន។

## ជំពូកទី២

## មុខសញ្ញាចំណាយនិងការគ្រោងឥណទានថវិកា

**ប្រការ ៥.-**

មុខសញ្ញាចំណាយកញ្ចប់ថវិកាសម្រាប់ប្រតិបត្តិការពង្រឹងគុណភាព និងលើកកម្ពស់សមធម៌សេវាសុខាភិបាល ចំពោះមន្ទីរពេទ្យបង្អែក និងមណ្ឌលសុខភាពមានជាអាទិ៍ដូចខាងក្រោម÷

- ចំណាយចាំបាច់ជាប្រចាំសម្រាប់ការងាររដ្ឋបាល រួមមានជាអាទិ៍ ការទិញសម្ភារតូចតាច ការជួសជុល និងការថែទាំអនាម័យនិងបរិស្ថាន
- ចំណាយសម្រាប់សង្គ្រោះជាបន្ទាន់ និងចាំបាច់
- ចំណាយទិញឱសថបឋម និងបរិក្ខារពេទ្យតូចតាច
- ការផ្សព្វផ្សាយនិងវិធានការលើកកម្ពស់គុណភាពសេវាសុខាភិបាលផ្សេងៗទៀត

**ប្រការ ៦.-**

ការណែនាំមុខសញ្ញាចំណាយលម្អិតខាងលើ និងនីតិវិធីអនុវត្ត ត្រូវកំណត់ដោយសេចក្តីណែនាំស្តីពីនីតិវិធីគ្រប់គ្រងប្រតិបត្តិការកញ្ចប់ថវិកាសម្រាប់ប្រតិបត្តិការពង្រឹងគុណភាព និងលើកកម្ពស់សមធម៌សេវាសុខាភិបាលរបស់ក្រសួងសុខាភិបាល។

**ប្រការ ៧.-**

កញ្ចប់ថវិកាសម្រាប់ប្រតិបត្តិការពង្រឹងគុណភាព និងលើកកម្ពស់សមធម៌សេវាសុខាភិបាល ចំពោះមន្ទីរពេទ្យបង្អែក និងមណ្ឌលសុខភាព ត្រូវគ្រោងក្នុងអនុគណនីលេខ ៦២០២៨ (ជំនួយសង្គមផ្សេងៗទៀត) នៃកញ្ចប់ថវិការបស់ក្រសួងសុខាភិបាល ឬមន្ទីរសុខាភិបាល។

**ប្រការ ៨.-**

គោលការណ៍នៃការកំណត់កញ្ចប់ថវិកាសម្រាប់ប្រតិបត្តិការពង្រឹងគុណភាព និងលើកកម្ពស់សមធម៌សេវាសុខាភិបាលចំពោះមន្ទីរពេទ្យបង្អែកនិងមណ្ឌលសុខភាពនីមួយៗ ត្រូវកំណត់ដោយក្រសួងសុខាភិបាល និង ត្រូវជាកម្មវត្ថុនៃការពិភាក្សានិងឯកភាពគ្នាជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ជំពូកទី ៣

## នីតិវិធីនៃការអនុវត្តថវិកា

### ផ្នែកទី ១

### ការបើកផ្តល់សាច់ប្រាក់

**ប្រការ ៩.-**

កញ្ចប់ថវិកាសម្រាប់ប្រតិបត្តិការពង្រឹងគុណភាព និងលើកកម្ពស់សមធម៌សេវាសុខាភិបាល ចំពោះមន្ទីរពេទ្យបង្អែកនិងមណ្ឌលសុខភាព ត្រូវបើកផ្តល់សាច់ប្រាក់ប្រចាំត្រីមាស ដោយអាណត្តិបើកប្រាក់។

**ប្រការ ១០.-**

អាណាប័កផ្ទេរសិទ្ធិ ត្រូវបោះអាណត្តិបើកប្រាក់ប្រចាំតាមត្រីមាស រួចផ្ញើជូនមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី-ខេត្ត ដើម្បីពិនិត្យ និងសម្រេច ក្នុងនាមអភិបាលហិរញ្ញវត្ថុ ។

អភិបាលហិរញ្ញវត្ថុពិនិត្យនិងសម្រេច រួចបញ្ជូនទៅ រតនាគាររាជធានី-ខេត្ត ក្នុងនាមគណនេយ្យករសាធារណៈ ដើម្បីពិនិត្យសម្រេចនិងបើកផ្តល់សាច់ប្រាក់។

**ប្រការ ១១.-**

រតនាគាររាជធានី-ខេត្ត ត្រូវបង្វែរសាច់ប្រាក់ ចូលគណនីនៃមន្ទីរពេទ្យបង្អែក និងមណ្ឌលសុខភាព ដោយប្រើប្រាស់ប្រព័ន្ធធនាគារ។

ក្រសួងសុខាភិបាល ត្រូវជ្រើសរើសធនាគារដៃគូណាមួយសមស្របតាមការឯកភាពរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីឱ្យមន្ទីរពេទ្យបង្អែកនិងមណ្ឌលសុខភាព បើកគណនីសម្រាប់កិច្ចប្រតិបត្តិសាច់ប្រាក់របស់ខ្លួន។

បន្ទាប់ពីទទួលបានការឯកភាពលើការជ្រើសរើសធនាគារ មន្ទីរសុខាភិបាលរាជធានី-ខេត្ត ត្រូវណែនាំដល់គ្រប់មន្ទីរពេទ្យបង្អែក និងមណ្ឌលសុខភាពក្រោមនិវាទ ដើម្បីដំណើរការបើកគណនីរៀងៗខ្លួន បន្ទាប់មកមន្ទីរសុខាភិបាលរាជធានី-ខេត្ត ប្រមូលឯកសារពាក់ព័ន្ធការបើកគណនីនេះ ដើម្បីបូកសរុបផ្តល់ជូនរតនាគាររាជធានី-ខេត្ត។

## ផ្នែកទី២
## ការគ្រប់គ្រងថវិកា

**ប្រការ ១២.-**

ប្រធានមន្ទីរពេទ្យបង្អែក ឬប្រធានមណ្ឌលសុខភាព ត្រូវចាត់តាំងមន្ត្រីគ្រប់គ្រងហិរញ្ញវត្ថុ ដើម្បីជាសេនាធិការគ្រប់គ្រង និងទទួលខុសត្រូវលើរាល់ការចំណាយថវិការបស់អង្គភាពខ្លួន ដើម្បីអោយកិច្ចដំណើរការក្នុងការផ្តល់សេវារបស់មន្ទីរពេទ្យបង្អែក និងមណ្ឌលសុខភាព ទទួលបាននូវប្រសិទ្ធិភាព ស័កសិទ្ធិភាព តម្លាភាព និងគណនេយ្យភាព។

## ផ្នែកទី ៣
## ការអនុវត្តចំណាយ និង កិច្ចបញ្ជិកាគណនេយ្យ

**ប្រការ ១៣.-**

វិធាននៃការអនុវត្តចំណាយកញ្ចប់ថវិកាសម្រាប់ប្រតិបត្តិការពង្រឹងគុណភាព និងលើកកម្ពស់សមធម៌សេវាសុខាភិបាល ចំពោះមន្ទីរពេទ្យបង្អែក និងមណ្ឌលសុខភាព ត្រូវអនុវត្តតាមនីតិវិធីរួមបច្ចុប្បន្នកម្មសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុគម្រោង អនុលោមភាពតាមអនុក្រឹត្យលេខ៧៤អនក្រ.បក ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១២ ស្តីពីការដាក់ឱ្យប្រើប្រាស់នីតិវិធីរួមបច្ចុប្បន្នកម្ម សម្រាប់ការអនុវត្តគម្រោងហិរញ្ញប្បទានសហប្រតិបត្តិការពីដៃគូអភិវឌ្ឍន៍។

**ប្រការ ១៤.-**

មន្ត្រីគ្រប់គ្រងហិរញ្ញវត្ថុរបស់មន្ទីរពេទ្យបង្អែក និងមណ្ឌលសុខភាព ត្រូវកត់ត្រាចំណូល-ចំណាយ ក្នុងកិច្ចបញ្ជិកាគណនេយ្យ ដូចខាងក្រោម ÷

- កិច្ចបញ្ជិកាគណនេយ្យហិរញ្ញកិច្ច (ប័ណ្ណចំណូល ប័ណ្ណចំណាយ និង បញ្ជីបេឡា)
- កិច្ចបញ្ជិកាគណនេយ្យសម្ភារ (ប័ណ្ណបញ្ចូលសម្ភារទំនិញ ប័ណ្ណបញ្ចេញសម្ភារទំនិញ និង បញ្ជីវិភាគសម្ភារទំនិញ) ។

## ជំពូកទី៤
## ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ

**ប្រការ ១៥.-**

មន្ទីរពេទ្យបង្អែក និងមណ្ឌលសុខភាព ត្រូវរៀបចំរបាយការណ៍ហិរញ្ញវត្ថុនៃការអនុវត្តចំណាយថវិកាប្រចាំត្រីមាស ឆមាស និងឆ្នាំ ទៅការិយាល័យសុខាភិបាលស្រុកប្រតិបត្តិ /ឬទីភ្នាក់ងារប្រតិបត្តិការពិសេស /ឬ មន្ទីរសុខាភិបាលរាជធានី-ខេត្ត លើកលែងត្រីមាសទី៤ ត្រូវបញ្ជូនឱ្យបានមុនថ្ងៃទី៣១ ខែធ្នូ នៃឆ្នាំនីមួយៗ ។

មន្ត្រីគ្រប់គ្រងហិរញ្ញវត្ថុរបស់មន្ទីរពេទ្យបង្អែក និងមណ្ឌលសុខភាព ត្រូវប្រមូលឯកសារ លិខិតយុត្តិការ និងសក្ខីបត្រចំណាយ ដែលមានការចុះហត្ថលេខាឯកភាពពីប្រធានមន្ទីរពេទ្យបង្អែក ឬប្រធានមណ្ឌលសុខភាព រួមមាន លិខិតស្នើសុំថវិកា វិក្កយបត្រ ឬសក្ខីបត្រចំណាយផ្សេងៗនិងប័ណ្ណចំណាយ និងត្រូវរក្សាទុកនៅតាមសាមីមន្ទីរពេទ្យបង្អែក និងមណ្ឌលសុខភាព សម្រាប់ធ្វើជាកម្មវត្ថុនៃសវនកម្មក្រោយចំណាយរបស់ស្ថាប័នមានសមត្ថកិច្ចផ្សេងៗស្របតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន។

**ប្រការ ១៦.-**

ការិយាល័យសុខាភិបាលស្រុកប្រតិបត្តិ និងទីភ្នាក់ងារប្រតិបត្តិការពិសេស ត្រូវប្រមូលតារាងរបាយការណ៍ចំណាយ ពីមន្ទីរពេទ្យបង្អែក និង មណ្ឌលសុខភាពរបស់ខ្លួន បន្ទាប់មករៀបចំ និងបូកសរុបជាតារាងរបាយការណ៍រួចបញ្ជូន នៅរៀងរាល់ដើមខែ នៃត្រីមាសបន្ទាប់ ទៅមន្ទីរសុខាភិបាលរាជធានី-ខេត្ត លើកលែងត្រីមាសទី៤ ដែលត្រូវបញ្ជូនឱ្យបានមុនថ្ងៃទី ០៥ ខែមករា នៃឆ្នាំបន្ទាប់ ។

មន្ទីរសុខាភិបាលរាជធានី-ខេត្ត ត្រូវប្រមូលរបាយការណ៍ចំណាយថវិកា ពីការិយាល័យសុខាភិបាលស្រុកប្រតិបត្តិ ទីភ្នាក់ងារប្រតិបត្តិការពិសេស និងមន្ទីរពេទ្យបង្អែករាជធានី-ខេត្ត ដើម្បីរៀបចំបូកសរុបជារបាយការណ៍ចំណាយថវិកា រួចបញ្ជូនទៅក្រសួងសុខាភិបាល មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី-ខេត្ត និងរតនាគាររាជធានី-ខេត្ត នៅរៀងរាល់ចុងខែទី១ នៃត្រីមាសបន្ទាប់ លើកលែងត្រីមាសទី៤ ដែលត្រូវបញ្ជូនយ៉ាងយូរបំផុតត្រឹមថ្ងៃទី ១០ ខែមករា នៃឆ្នាំបន្ទាប់។

## ជំពូកទី៥
## អន្តរប្បញ្ញត្តិ

**ប្រការ ១៧.-**

សម្រាប់ការចាប់ផ្តើមអនុវត្តកញ្ចប់ថវិកាសម្រាប់ប្រតិបត្តិការពង្រឹងគុណភាព និងលើកកម្ពស់សមធម៌សេវាសុខាភិបាល អនុញ្ញាតឱ្យអាណាប័កផ្ទេរសិទ្ធិ បោះអាណត្តិបើកប្រាក់លើកដំបូងសម្រាប់ទ្រទ្រង់ចំណាយប្រតិបត្តិការរយៈពេល៦ខែ ជូនដល់មន្ទីរពេទ្យបង្អែកនិងមណ្ឌលសុខភាព។

## ជំពូកទី៦
## អវសានប្បញ្ញត្តិ

**ប្រការ ១៨.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសអន្តរក្រសួងនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ១៩.-**

ថ្នាក់ដឹកនាំ នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយក អគ្គាធិការ ប្រធាននាយកដ្ឋាន និងប្រធានគ្រប់អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងសុខាភិបាល ត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែមីនា ឆ្នាំ ២០១៦

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន

**រដ្ឋមន្ត្រីក្រសួងសុខាភិបាល**

ម៉ម ប៊ុនហេង

កន្លែងទទួល ÷

- ទីស្ដីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេច ឯកឧត្ដម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- សាលារាជធានី ខេត្ត
- ដូចប្រការ១៩
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ